Declassified to Public
06 September 2012

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction
សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No.................................

# កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី
# Written Record of Interview of witness
# Procès-verbal d'audition de témoin

ឆ្នាំពីរពាន់ប្រាំពីរ ខែកញ្ញា ថ្ងៃទីម្ភៃប្រាំ នៅវេលាម៉ោងប្រាំបួននិងសាបសិបប្រាំនាទីព្រឹកនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

យើង ស៊ឹម សុរិយ៉ា(សស), ងួន អ៊ឹម (ងអ), Christian Baudesson (CB), Fabienne Luco (FL) ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានចាត់ដោយដីកាចាត់អោយស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី២៧ខែ សីហា ឆ្នាំ២០០៧

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤
បានឃើញវិធាន ២៤ ២៨ និង៦០ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

☒ ដោយមានវត្តមានរបស់ លោក តាន់ ប៉ាងដារ័ណ្ណ ជាអ្នកបកប្រែភាសារបស់អង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ។

បានកត់ត្រាយកចម្លើយពីឈ្មោះ ប្រាក់ ខន ជាសាក្សីដែលបានផ្តល់ព័តមានស្តីពីអត្តសញ្ញាណដូចខាងក្រោម:
ឈ្មោះ ប្រាក់ ខន ឈ្មោះបដិវត្ត ..............អត់មាន...........កើតថ្ងៃទី៧ ខែមករា............ឆ្នាំ.១៩៥១...........នៅភូមិ...ក្រាំងលាវ.........ឃុំ-សង្កាត់ក្រាំងលាវ..................ស្រុក-ខណ្ឌ.បាទី..................ខេត្តតាកែវ សញ្ជាតិ ខ្មែរ.....របរ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

រកស៊ី............លក់ដូរ និងធ្វើស្រែ...............ឪពុកឈ្មោះ ....ប្រាក់ ម៉ន...........................“រ”ម្តាយឈ្មោះ ម៉េង វ៉ាន់...................“ស”

ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ..........ផ្លូវលេខ..........ភូមិ...ស្មៅខ្ញី..........ឃុំ-សង្កាត់..ត្រពាំងសាប.........ស្រុក-ខណ្ឌ.បាទី..... ខេត្ត-ក្រុង.........តាកែវ........ប្រពន្ធឈ្មោះ វាល់ ហាក់ “រ” មានកូន.ប្រាំ.....នាក់ ទោសពីមុនមិនដែលមានទោសអ្វីទេ។

☒ ជននេះ បានប្រកាសថាខ្លួនចេះអាន សរសេរ និងយល់ ភាសា.........ខ្មែរ..........

☒ ជននេះ បានប្រកាសថាខ្លួនមិនចេះអាន និង សរសេរភាសា.........ដទៃ

ហេតុដូច្នេះ ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសា............. ខ្មែរ.....................

☒ យើង បានជូនព័តមានរួចហើយដល់ជននេះថា ការស្តាប់យកចម្លើយនេះ នឹងត្រូវថតយកសម្លេង ឬ រូបភាព។

☒ ជននេះបានប្រាប់យើងពីទំនាក់ទំនងរបស់គេជាមួយនឹងជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីថា មិនទាក់ទង

☒ ជននេះ បានស្បថ ស្របតាមបញ្ញត្តិនៃវិធាន ២៤ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

☒ យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ស្របតាមបញ្ញត្តិនៃវិធាន ២៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ។

សួរ-ឆ្លើយៈ

CB: ថ្ងៃហ្នឹងគាត់ចង់សួរពីតើការធ្វើទារុណកម្មនៅពេលសួរចម្លើយ សំណួរទីមួយគឺថា តើទារុណកម្មហ្នឹងគឺធ្វើដោយស្វ័យប្រវត្តិឬយ៉ាងម៉េច?

បខ: កាលណាមានការអនុញ្ញាត្តិពីឌុចអីហើយហ្នឹង ពេលសួរហ្នឹងគឺការធ្វើទារុណកម្មមានជាបន្ត បន្ទាប់កាលណាមានការអនុញ្ញាតិពីខាងលើហើយ។

CB: អញ្ចឹងបានន័យថាគ្រប់ការសួរចម្លើយទាំងអស់ យើងមានសិទ្ធិក្នុងការធ្វើទារុណកម្មបើអ្នកទោសមិនឆ្លើយទៅតាមអ្វីដែលយើងសួរទេ?

បខ: បាទ!

FL: ហើយអ្នកណាជាអ្នកបញ្ជា? ហើយបញ្ជាយ៉ាងដូចម្តេច?

បខ: ឌុចហ្នឹងហ្នុង ឱ្យធ្វើទារុណកម្មយ៉ាងម៉េចឱ្យបានចេញចម្លើយ។

FL: អញ្ចឹងបញ្ជាដែលយើងមានសិទ្ធិធ្វើទារុណកម្មពីឌុចហ្នឹងជាបញ្ជាផ្ទាល់មាត់អីក៏លាយលក្ស័អក្សរ?

បខ: ជួនកាលតាមផ្ទាល់មាត់ ជួនកាលតាមទូរសព្ទ័ ពេលខ្លះខ្ញុំសួរទៅមិនទាន់និយាយអីខ្ញុំសុំយោបល់ ខ្ញុំថាបងខ្ញុំសួរគាត់អត់និយាយទេ គាត់ថាអញ្ចឹងធ្វើទារុណកម្មទៅ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00146595

សស: ឧបករណ៍ដែលប្រើហ្នឹង មានលក្ខណៈជារួម អ្នកសួរចម្លើយត្រូវប្រើដូចគ្នា ឬក៏ស្រេចតែអ្នក សួរចម្លើយរកដោយខ្លួនឯង ឬក៏ឌុចហ្នឹងបង្គាប់ឱ្យប្រើ?

បខ: ឧបករណ៍ដែលយកម៉ោធ្វើទារុណកម្មគឺមិនបង្គាប់បញ្ជាទេ គឺជាក់ស្តែងមានអីធ្វើហ្នឹង ដូចជាខ្សែ ភ្លើង ដង្កាប់ដកក្រចក យកម្ជុលចាក់ក្រចកអីហ្នឹង ជាក់ស្តែងគឺយើងមានអីធ្វើហ្នឹង។

ងអ: គំនិតផ្តើមសម្រាប់ការធ្វើទារុណកម្មហ្នឹង ការដកក្រចក ការយកម្ជុលចាក់នៅក្នុងក្រចកអីជា ដើម ឬឆក់ខ្សែភ្លើង តើដំបូងឡើយអ្នកណាជាអ្នកណែនាំឱ្យធ្វើអញ្ចឹង?

បខ: អញ្ចឹងក្នុងការធ្វើទារុណកម្មគំនិតផ្តើមដំបូងហ្នឹងវាគ្មានអ្នកណាប្រាប់ធំដំទេ តែក្រោយៗម៉ោគេ ប្រាប់ថា ឱ្យធ្វើទារុណកម្មគ្របស្បោងកៅស៊ូ ឆក់ខ្សែភ្លើង ដើម្បីកុំឱ្យខ្មាំងដំបៅពេញខ្លួន របួសពេញខ្លួន ហើយបញ្ជាចាក់ក្រចកជាបញ្ជាបន្ទាប់បន្សំ ធ្វើយ៉ាងម៉េចឱ្យតែបានចម្លើយ។

ងអ: ខ្ញុំទទួលបានហើយ ប៉ុន្តែខ្ញុំចង់ដឹង ព្រោះលោកអ្នកសួរចម្លើយ ប៉ុន្តែគំនិតផ្តើមដើម្បីធ្វើ ទារុណកម្មហ្នឹង កម្រមានពីណានឹកឃើញណាស់ ចង់និយាយថាអ្នកដែលមាន ពិសោធន៍ដែលគេ ផ្តល់គំនិតហ្នឹងពីដំបូងម៉ោ?

បខ: អារឿងធ្វើទារុណកម្មដកក្រចក គំនិតផ្តើមហ្នឹងគឺឌុចណែនាំថាវាជាការងារធ្វើទារុណកម្មបន្ទាប់ បន្សំ ចៀសវាងរបួសខ្លួនរបួសអី កាលណាវិធីណាមិនបានការអញ្ចឹងវិធីដែលប្រើហ្នឹងគឺបួនប្រាំវិធីហ្នឹង។

ងអ: លោកអាចរំលឹកឡើងវិញមើលទាក់ទងនឹងការធ្វើទារុណកម្មហ្នឹងដូចឆក់ខ្សែភ្លើងអី បើមិនបាន ចម្លើយហើយតើមានទារុណកម្មអីផ្សេងទៀតទេ?

បខ: អារឿងទារុណកម្មតាមខ្ញុំនឹកទៅដូចវាមិនខុសប្លែកពីខ្ញុំនិយាយទេ ទី១វ៉ៃ ទី២ឆក់ខ្សែភ្លើង ទី៣ច្រកស្បោង ទី៤ចាក់និងដកក្រចក។

សស: ការធ្វើទារុណកម្មទាំងអស់ហ្នឹងមានដែលរហូតដល់អ្នកទោសហ្នឹងស្លាប់ដែរ?

បខ: ការធ្វើទារុណកម្មហ្នឹងខ្ញុំមិនដែលប្រទះរហូតដល់ស្លាប់ទេ ព្រោះប្រយ័ត្នប្រយែងតាំងពីដើម ដំបូងម៉ោ។

សស: ចុះចំពោះករណីអ្នកសួរចម្លើយផ្សេងដែលមានករណីសួររហូតដល់ស្លាប់ទេ? ដែលមានទារុណ កម្មរហូតដល់ស្លាប់ទេ?

បខ: ចំពោះអ្នកផ្សេងគឺមាន មានខ្លះវ៉ៃដល់ស្លាប់ ខ្លះឆក់ខ្សែភ្លើងដល់ស្លាប់ក៏មាន ខ្លះច្រកស្បោងដល់ ស្លាប់ក៏មាន។

សស: ក្នុងករណីនោះតើឌុចមានវិធានការណ៍ពិន័យ ឬក៏ណែនាំយ៉ាងដូម្តេច?

បខ: ក្រោយពីមានព្រឹត្តិការណ៍ហើយហ្នឹង ឌុចហៅទៅណែនាំនៅសាលានយោបាយនៅជិតផ្ទះឌុចពីបញ្ហាធ្វើទារុណ កម្មដល់ខ្មាំងស្លាប់ ឱ្យខ្មាំងធ្វើវិច្ឆេតកម្ម ពេលមានព្រឹត្តិការណ៍អីគឺហៅអ្នកសួរចម្លើយទៅរៀនសូត្រ គ្រប់ពេលវេលាទាំងអស់ ឧទារហណ៍វ៉ៃខ្មាំងស្លាប់ហើយ៤-៥ថ្ងៃគឺហៅទៅរៀនសូត្រហើយ ខ្លះ ពេលសួរខ្មាំង ហើយពេលភ្លើងដាច់អីចឹងយកភ្លើងចង្កៀងទៅដុត ហើយខ្មាំងយកចង្កៀងហ្នឹងទៅស្រោចដុតខ្លួន ខ្លះយកប៊ិចទៅចាក់កករ នេះជាការធ្វើវិច្ឆេតកម្មរបស់ខ្មាំងនៅក្នុងគុក។

សស: បងលើកឧទាហរណ៍មើលការសួរចម្លើយដែលដល់ស្លាប់ហ្នឹង មានចាំឈ្មោះអ្នកសួរចម្លើយ ដែលបាត់ខ្លួនហ្នឹង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boîte postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

មានចាំឈ្មោះខ្លះទេ?

បខ: ខ្ញុំនឹកឡើងអ្នកដែលធ្វើទារុណកម្មស្លាប់អ្នកទោសហើយស្លាប់ហ្នឹងខ្ញុំចាំមិនច្បាស់ទេ កាលហ្នឹង ដូចជាមានឈ្មោះចុម។

សស: ចុះស៊ឹម ម៉េលហៅម៉ាន?

បខ: ម៉ានហ្នឹងក៏ធ្វើឱ្យមនុស្សស្លាប់ដែរ ក្រោយម៉ោក៏គេចាប់ដែរម៉ានហ្នឹង ជនជាតិចាម ប្រធានក្រុម របស់ខ្ញុំ។

FL: ឆ្នាំណា?

បខ: អត់ចាំដែរ។ មួយទៀតឈ្មោះទូច ជាជំនិតរបស់ចាន់ហ្នឹង ដល់អញ្ចឹងចាន់ឱ្យទូចហ្នឹងយកមនុស្ស ស្រីសួរ ដល់ពេលហ្នឹងខុសសីលធម៌ជាមួយនារី ដល់ទៅទាន់ក៏ចាប់ទូចហ្នឹងយកទៅដាក់ខ្នោះនៅផ្ទះ ចាន់ហ្នឹង ដល់ពេលហ្នឹងទូចលោតពីលើផ្ទះបីជាន់ពីលើម៉ោ ជាប់លើខ្សែកាប តែធ្លាក់ម៉ោអត់ងាប់ ចាប់ យកម៉ោដាក់ខ្នោះម៉ាសារទៀត ដល់ក្រោយម៉ោលោតម៉ាសារទៀត ក្រោយម៉ោបានចាប់យកម៉ោ ដាក់នៅគុកធំ ចុងក្រោយបានគេសម្លាប់ចោល។

CB: ចង់និយាយថាគាត់មានបញ្ហាសីលធម៌ហ្នឹងពេលសួរចម្លើយ ឬក៏នៅពេលណា?

បខ: គឺនៅក្នុងបន្ទប់សួរចម្លើយហ្នឹងហ្មង។

CB: អញ្ចឹងលោកពូដឹងថា ការរំលោភអ្នកទោសស្រីហ្នឹងញឹកញាប់ទេ?

បខ: រំលោភហ្នឹងខ្ញុំដឹងតែម្នាក់ទេ ព្រោះនៅជាប់ខ្ញុំ ខ្ញុំនៅពីមុខគេនៅពីក្រោយ ហើយធម្មតាអ្នកទោស ស្រីយកម៉ោអត់មានដាក់ខ្នោះដៃ អត់មានចងមុខ ដល់ពេលសួរបានដាក់ខ្នោះ ជើង ដល់ពេលនាំចូលបន្ទប់វិញ ចូលបត់ដៃបត់ជើងអីហ្នឹងអាណឹងឱ្យចូលទទេហ្មងអត់មានដាក់អី ទេ។

CB: អញ្ចឹងយើងគិតថា អ្នកទោសស្រីហ្នឹងគឺសួរដោយអ្នកសួរចម្លើយប្រុសអត់មានអ្នកសួរស្រីទេ?

បខ: ដូចខ្ញុំនិយាយកាលមុនអញ្ចឹង កាលមុនមានអ្នកសួរស្រី ដល់ក្រោយម៉ោគេចាប់អស់ទៅប្រគល់ ឱ្យប្រុសៗសួរដែរ។

CB: អញ្ចឹងបានន័យថា តាំងពី៧៧ម៉ោតាំងពីគេចាប់អ្នកសួរចម្លើយស្រីអស់ទៅ តាំងពីពេលហ្នឹងម៉ោ សួរដោយអ្នកសួរប្រុសទាំងអស់?

បខ: បាទ!

សស: បងមានដែលសួរជនជាតិវៀតណាម ឬភាគតិចអី មានដែលសួរទេ? បើសិនជាសួរនិយាយ ភាសារម៉េចកើតទៅ?

បខ: ចំពោះខ្ញុំសួរចំពោះជនជាតិវៀតណាមអត់ដែលសួរទេព្រោះខ្ញុំអត់ចេះវៀតណាម ចំពោះជនជាតិ ភាគតិចដែលចេះភាសារខ្មែរអាណឹងមានសួរ តែភ្លេចឈ្មោះអីហើយ ម៉ោពីភាគឥសាន មានគ្រឹង គួយ ទំពួន។

CB: គាត់និយាយភាសារខ្មែរ?

បខ: បាទ!

FL: ចំពោះអ្នកទោសដែលជាវៀតណាម ឬថៃ ឬបរទេសផ្សេងទៀតហ្នឹងគេមានអង្គភាពពិសេស អីទៀតសម្រាប់សួរទេ?

បខ: ខ្ញុំឃើញតែចាន់ ប៉ុន ម៉េង ដែលជាសាស្ត្រាចារ្យចេះភាសារច្រើន ហើយពេលណាខ្លះឌុចសួរ ផ្ទាល់។

FL: ឌុច គាត់សួរជនជាតិអីគេ?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

បខ: ខ្ញុំឃើញដូចជា អូស្ត្រាលី អាមេរិកាំង ដូចចាំម្នាក់ដូចជា តេរីឌ ស្កុត អាមេរិកាំង។

FL: ឧុចជាអ្នកសួរផ្ទាល់?

បខ: ឃើញឌុច ឃើញចាន់ ព្រោះសួរចម្លើយបរទេសអត់មានយកទៅសួរក្រៅទេ គឺសួរជាសាធារណៈហ្នឹងព្រោះអត់មាននរណាស្តាប់បានទេ។

CB: អញ្ចឹងលោកផ្ទាល់ឃើញផ្ទាល់ភ្នែកទេ?

បខ: ខ្ញុំឃើញផ្ទាល់ព្រោះខ្ញុំយកអ្នកទោសទៅទុកខ្ញុំឃើញសួរ ខ្ញុំឈរស្តាប់តែខ្ញុំស្តាប់មិនបាន សួរជា ភាសារអង់គ្លេស ឈ្មោះវាតេរីតស្កុត សរសេរនៅនឹងអារ នៅលេវអារឈើផ្តាក់ ហើយខ្ញុំមើលរួច ហើយគឺតេរីដស្កុត ផ្តាក់ឈ្មោះហ្នឹងហ្នឹងគ្រប់លេវ។

CB: ពេលលោកឈរស្តាប់ហ្នឹងលោកឃើញឌុចធ្វើទារុណកម្មអ្នកទោសហ្នឹងទេ?

បខ: ខ្ញុំឃើញឌុចសួរហើយទាត់ ដល់ពេលសួរហើយវាឆ្លើយថាវាជាជនជាតិអាមេរិកាំង ម្នាក់ជាជន ជាតិអូស្ត្រាលី ជិះទូកថ្មចូលម៉ោហ្នឹងមានរបស់របបរស៊ីគ្រប់គ្រាន់បីខែ ចូលម៉ោដើម្បីស៊ើបការណ៍ពី ស្រុកខ្មែរ។

អង: គេឆ្លើយថាទូកស៊ីម៉ង់អញ្ចឹង?

បខ: អាណឹងពេលសួរហើយគេនិយាយជាមួយចាន់ហ្នឹងថាគេជិះទូកស៊ីម៉ង់ម៉ោ ហើយពីរនាក់ហ្នឹងទៀតពេលយកទៅសម្លាប់ចោលខ្ញុំដឹងតាមរយៈសឿ អញ្ចឹងសឿហ្នឹងថាយកទៅចងដាក់ខ្មោះ ចងសេក ហ្នឹងហើយដាក់នៅកណ្តាលថ្នល់ទៅទួលទំពូង ដាក់នៅកាច់ជ្រុង ហើយយកអាកង់ឡាន ចាស់ៗហ្នឹងដាក់ជុំវិញខ្លួនហើយ ពាក់ក្បាលចាក់សាំងដុតបណ្តោយ។

CB: លោកមើលឃើញ?

បខ: ខ្ញុំអត់ឃើញទេ តែសឿ ប្រាប់ខ្ញុំ សឿនៅកំពង់ឆ្នាំង កំពង់ត្រឡាច។

ងអ: សឿហ្នឹងគាត់អ្នកការពារដែរ?

បខ: គាត់កងការពារនៅផ្នែកច្រកហ្នឹងហ្នឹង។

FL: តើមានបច្ចេកទេសប្លែកគ្នាទេរវាងអ្នកទោសខ្មែរ និងបរទេស?

បខ: ការសួរចម្លើយមិនដូចគ្នាទេ ព្រោះអ្នកទោសបរទេសសួរជាសាធារណៈអត់មានលាក់ការណ៍អី ទេ ព្រោះគ្មានណាគេស្តាប់បាន ហើយសួរមិនយូរ សួរមិនច្រើន អញ្ចឹងវាអត់ដូចខ្មែរយើង អានោះសួរ តែម៉ាថ្ងៃពីរថ្ងៃអីបាត់ហើយចប់ហើយ។

CB: អញ្ចឹងអ្នកទោសអាមេរិកាំង និងអូស្ត្រាលីពីរនាក់ហ្នឹងគេសួរតែពីរបីថ្ងៃគេសម្លាប់?

បខ: បាទ! បើវៀតណាមច្រើនជាកងទ័ព ហើយចាន់ជាអ្នកសួរ ហើយសរសេរជាឯកសារហើយឱ្យអ្នកទោសហ្នឹងស្មុគ្រហើយចត ហើយចាក់វ៉ាឌីយ៉ូថាវៀតណាមចូលមកស៊ើបការក្នុងស្រុកខ្មែរ។

FL: ជាពិសេសនៅឆ្នាំណា?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boîte postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00146598

បខ: ចាក់ផ្សាយជាភាសាវៀតណាម បកប្រែជាភាសាខ្មែរម៉ាម៉ាត់ៗនៅឆ្នាំ៧៨, ៧៩។

ងអ: ថ្ងៃ៦ ខែ១ហ្នឹងបែកហើយ?

បខ: ខ្ញុំចាំមិនច្បាស់ដែរ តែមុនវៀតណាមចូលម៉ោហ្នឹងគឺចាក់ផ្សាយវៀតណាមហ្នឹងរាល់ថ្ងៃហ្នុង។

FL: លោកជម្រាបថាមានការខុសគ្នារវាងការសួរខ្មែរ និងបរទេស ចំពោះបរទេសហ្នឹងមានការប្លែក គ្នាទេក្នុងការសួរ?

បខ: សួរដូចប្លែកពីខ្មែរ ព្រោះខ្មែរសួររកឫសគល់ ដល់បរទេសសួរថា អ្នកឯងម៉ោខ្មែរហ្នឹងមានគោល បំណងអី ហើយឱ្យនិយាយជាភាសាវាហ្នឹងផ្សាយដល់ប្រទេសគេវិញ គ្រាន់តែឱ្យដឹងថាវាចូលម៉ោខ្មែរ សារភាព អត់មានសួររកឫសរកគល់អីទេ។

FL: ក្នុងចំណោមខ្មែរ និងមានជនជាតិភាគតិច តើមានការខុសគ្នាទេក្នុងការសួរ?

បខ: អត់មានទេ ការសួរហ្នឹងអត់មានការបែងចែកទេ គឺសួរដូចគ្នាទាំងអស់។

FL: អញ្ចឹងបើគ្មានការបែងចែករវាងពូជសាសន៍អីទេ អញ្ចឹងមានការបែងចែកប្រជាជនថ្មី ចាស់អី ដែរទេ?

បខ: ចំពោះអ្នកប្រជាជនថ្មី និងចាស់ គឺគេចម្រាញ់បំផុតហើយចំពោះអ្នកថ្មី ១៧ មេសា ដែលជាប់ និន្នាការជាមន្ត្រី ប៉ូលីសអីហ្នឹង។

CB: អញ្ចឹងបានន័យថាពេលសួរចម្លើយប្រជាជនថ្មី គឺសួរអ្នកហ្នឹងជារដ្ឋការ ឬក៏ជាប៉ូលីសអីចឹង?

បខ: អាណឹងត្រូវសាកសួរពីធ្លាប់ធ្វើការនៅភ្នំពេញ កាលពីលន់ ណុលធ្វើអីៗ និយាយរួមអ្នកប៉ូលីស រដ្ឋការអីហ្នឹងនិយាយជាហូរហែរជាសកម្មភាពក្បត់ហូរហែរ អាណឹងជាបណ្ដាញរបស់សេអ៊ីអាហ្នឹង តែម្ដង។

សស: បងឮវ៉ាឌីយ៉ូផ្សាយពីចម្លើយសារភាពរបស់វៀតណាមហ្នឹង តាមរយៈអីគេ តាមវ៉ាឌីយ៉ូគេ បំពាក់ នៅហ្នឹងហ្នុងអីក៏ម៉េច?

បខ: ផ្សាយជារឿងរាល់ថ្ងៃហ្នឹងគឺនៅកន្លែងខ្ញុំមានវ៉ាឌីយ៉ូមួយគ្រឿងប៉ាណាសូនិច ខ្ញុំបើកជារឿង រាល់ថ្ងៃ បើកបាន តែប៉ុស្ដិ៍មួយទេ ហើយជាក់ស្ដែងហ្នឹងគឺចាន់សួរជាភាសាវៀតណាមហើយផ្សាយ រាល់ថ្ងៃហ្នឹងហ្នុង។

សស: តើវ៉ាឌីយ៉ូហ្នឹងមាននៅផ្ទះអ្នកសួរចម្លើយ ឬក៏មាននៅគុកហ្នឹងហ្នុង?

បខ: កាលសម័យហ្នឹងមិនមែនថានៅកន្លែងសួរចម្លើយទេ និយាយរួមគឺដាក់បំពងសម្លេងនៅកន្លែង ណាមួយផ្សាយជាសាធារណៈហ្នុង កន្លែងខ្ញុំនៅឆ្ងាយអីអញ្ចឹង ខ្ញុំពិបាកស្ដាប់ គេដាក់ដោយឡែក។

សស: ខ្ញុំចង់សួរថានៅកន្លែងអ្នកទោសហ្នឹងមានវ៉ាឌីយ៉ូឱ្យអ្នកទោសស្ដាប់ដែរ?

បខ: នៅកន្លែងអ្នកទោសហ្នុងអត់មានទេ តែអាចឮទៅដល់។

សស: ចុះមុននឹងមានការឮពីចម្លើយសារភាពវៀតណាមហ្នឹង មានគេផ្សាយពីគោលនយោបាយរបស់ បក្ស ឬអីផ្សេងៗទៀតទេ?

បខ: តាមខ្ញុំបែក១៧មេសាហើយភ្លាមហ្នឹងគឺមានបើកជាប្រចាំហើយ មានផ្សាយពីគោលនយោបាយ របស់បក្ស ការបង្កបង្កើនផលតាមជនបទអីហ្នឹង និយាយរួមគឺបានដឹងឮរហូតម៉ោហ្នុង។

ងអ: ខ្ញុំវិលម៉ោកន្លែងលោកឆ្លើយមុនបន្តិច សួរអ្នកទោសបរទេសគឺប្លែកត្រង់សួរជាសាធារណៈ ខ្ញុំចង់ លោកបញ្ជាក់ថាសួរជាសាធារណៈហ្នឹងគេធ្វើយ៉ាងម៉េច?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

បខ: បានន័យថា កន្លែងយកទៅទុកទៅដាក់អីហ្នឹង ឧទាហរណ៍អាគារបេ អាគារដេអីហ្នឹង បន្ទប់ធំ ហ្នឹង អញ្ចឹងយកទៅដាក់ហ្នឹងដាក់ជាមួយខ្មែរដាក់អីខ្លះហ្នឹងគឺសួរនៅកន្លែងហ្នឹងហ្នង សួរនៅ កន្លែងដាក់ ហ្នឹងហ្នង សួរហើយចាំកត់ត្រាហ្នឹងហ្នង សួរម៉ាថ្ងៃពីរថ្ងៃហ្នឹង។

ងអ: គេសួរនៅក្នុងបន្ទប់ដែលដាក់អ្នកទោសរួមទាំងខ្មែរ និងបរទេស?

បខ: បាទ!

ងអ: ពេលគេសួរហ្នឹង របៀបដោះខ្នោះចេញពីដៃដែរអីយ៉ាងម៉េច?

បខ: ពេលសួរហ្នឹងគឺខ្នោះដៃជើងនៅជាប់ទាំងអស់ អត់មានដោះ ព្រោះអាមេរិកាំមាឌធំៗណាស់ អត់ ហ៊ានដោះទេ។

ងអ: ហើយក្រៅពីលោកបានឃើញផ្ទាល់ ថាឌុចបានទាត់ជនបរទេសហ្នឹង ក្រៅពីហ្នឹងលោកមានដែល ឃើញឌុចធ្វើទារុណកម្មអ្នកផ្សេងទេ?

បខ: ចំពោះឌុចដែលសួរអ្នកទោស អានេះជាអចិន្ត្រៃយ៍តាមខ្ញុំឃើញ ដូចថាពេលម៉ោកន្លែងខ្ញុំហ្នឹងគាត់ ឆ្លល់កន្លែងណាមួយទៅគាត់សួរ ដល់ហើយគាត់ដាក់ម៉ាដៃពីរដៃទៅ គាត់ដើរសួរគ្រប់កន្លែងទាំងអស់

ងអ: មានដែលអ្នកទោសស្រីដែលមានផ្ទៃពោះហៅសួរទេ?

បខ: ខ្ញុំអត់ដែលជួបទេ ប៉ុន្តែក្នុងហ្នឹងឃើញមាន។

ងអ: តើអ្នកទោសដែលមានផ្ទៃពោះហ្នឹងគេមានផ្ទៃពោះពីណាម៉ោ អីក៏នៅខាងក្នុងហ្នឹង?

បខ: ចំពោះអ្នកមានផ្ទៃពោះហ្នឹងឈ្មោះពេទ្យថន ពោះធំពីក្រៅម៉ោទេ មិនដឹងមានរឿងអីទេ ចាប់ យកម៉ោដាក់ក្នុងហ្នឹង ចាប់បានពីរបីខែ ហើយគេដោះលែងវិញ ឱ្យនៅក្រោមជណ្តើរអាគារបេ តែអត់ មានដាក់ខ្នោះដាក់អីទេ ដេកនៅហ្នឹង ហើយពេទ្យថនហ្នឹងទើបម៉ោពីចិន ហើយខាងចាក់ម្ជុលវិទ្យា សាស្ត្រ ខ្ញុំធ្លាប់ពេទ្យថនហ្នឹងព្យាបាលដែរ ប៉ុនក្រោយម៉ោពេទ្យថនហ្នឹងខ្ញុំមិនទាន់ឃើញគេចាប់យក ទៅសម្លាប់ទេ តែក្រោយម៉ោពេលរំដោះហ្នឹងបាត់។

ងអ: ប៉ុន្តែលោកបញ្ជាក់បន្តិចមើលមានធ្លាប់ឃើញអ្នកមានផ្ទៃពោះមានគេធ្វើទារុណកម្មដែរទេ?

បខ: ចំពោះអ្នកមានផ្ទៃពោះខ្ញុំមិនបានឃើញគេធ្វើទេ គ្រាន់តែដឹងថាមាននៅក្នុងគុកហ្នឹង ពីរបីខែ ក្រោយម៉ោគេដោះលែង អត់មានដាក់ខ្នោះដាក់អីទេ ដល់ពេលសម្រាលកូនហើយ កូនហ្នឹងកូនប្រុស ទៀត។

ងអ: នៅពេលដែលស្ថិតនៅក្នុងការសួរចម្លើយ ឬក្រោយសួរចម្លើយ ដែលមានអ្នកទោសធ្វើអត្តឃាត ខ្លួនឯងទេ?

បខ: អ្នកទោសធ្វើអត្តឃាដហ្នឹងមាន ខ្លះយកដែកខ្មៅ ឬក៏ប៊ិចហ្នឹងចាក់ខ្លួនឯង  បោកកែវយកម៉ោ ចាក់ខ្លួនឯង ខ្លះយកចង្កៀងដុតខ្លួនឯង ខ្លះលោតពីលើអាគារ អាណឹងមាន។

FL: លោកបាននិយាយពីមុនថា ឌុចហ្នឹងបានសួរចម្លើយ និងធ្វើទារុណកម្មស្រីម្នាក់ដោយឆក់ខ្សែ ភ្លើង លោកនិយាយម្តងទៀតបានទេ?

បខ: មានឌុច មានចាន់ មានទិត មានដែក ប៊ូ មានម៉េង មានប៉ុន ៥-៦នាក់ហ្នឹង គឺធ្វើទារុណកម្មចាប់ ពីម៉ោង៩យប់ទល់ម៉ោង៣ជិតភ្លឺ ខ្ញុំនៅយាមខាងក្រៅ ប៉ុនស្រីហ្នឹងខ្ញុំមិនចាំឈ្មោះទេ នៅខាងក្រៅគុក

ប៉ុន្តែនៅកន្លែងសួរចម្លើយរបស់ទិត ពេលធ្វើទារុណកម្មពេលហ្នឹងគឺអត់មានសារភាពទេ ទាល់តែអ្នក ទោសនារីហ្នឹងសន្លប់ ឆក់ខ្សែភ្លើងពេកទៅ វ៉ៃហើយឆក់ខ្សែភ្លើងសន្លប់អត់ដឹងខ្លួន។

FL: អ្នកណាអ្នកឆក់ខ្សែភ្លើង?

បខ: កាលហ្នឹងឌុច។

CB: សួរនៅកន្លែងណា?

បខ: នៅកន្លែងទិតសួរចម្លើយ។

FL: នៅឆ្នាំណា?

បខ: ខ្ញុំមិនអាចចាំឆ្នាំទេ។

FL: អ្នកទោសស្រីហ្នឹងឈ្មោះអី?

បខ: អត់ចាំ។

FL: តើលោកឃើញផ្ទាល់ភ្នែកទេ ដែលឌុចឆក់ខ្សែភ្លើង?

បខ: ខ្ញុំឃើញផ្ទាល់ភ្នែក ព្រោះពេលចប់ម៉ោងសួររបស់ខ្ញុំៗយកអ្នកទោសយកទៅទុក ខ្ញុំយាមនៅខាង ក្រៅ ខ្ញុំយាមដូចខ្ញុំឈរមើលអញ្ចឹង។

CB: អញ្ចឹងលោកនៅក្នុងបន្ទប់?

បខ: ខ្ញុំនៅខាងក្រៅមាត់ទ្វារ។

CB: អញ្ចឹងលោកមើលតាមទ្វារអញ្ចឹងឃើញ?

បខ: ខ្ញុំនៅមាត់ច្រកហ្នឹងហ្មង ឃើញ ហើយទ្វារដែកហ្នឹងរុញអស់រលីង ផ្ទះល្វែង អង្គុយនៅមាត់ទ្វារ ហ្នឹងឃើញ។

FL: អញ្ចឹងលោកអាចបង្ហាញឱ្យច្បាស់ទេ តើមានសកម្មភាពអ្វីខ្លះ?

បខ: កាលហ្នឹងឌុចសួរ ដូចជាថាចង់បានពត៌មានសំខាន់កាលហ្នឹង ប៉ុន្តែសួរទៅវាមិនចេញ អញ្ចឹងឌុចធ្វើ ទារុណកម្មវ៉ៃ ឆក់ខ្សែភ្លើង ដោះអាវចេញ នៅតែខោវែង ធ្វើទារុណកម្មជាមួយដែក ប៊ូ, ម៉េង, ប៉ុន, ចាន់ អីហ្នឹង។

FL: អញ្ចឹងក្នុងចំណោមហ្នឹងឌុចជាអ្នកសួរ និងធ្វើទារុណកម្ម សកម្មជាងគេ?

បខ: កាលធ្វើហ្នឹង ទារុណកម្មហ្នឹងឌុចធ្វើមិនច្រើនជាងគេប៉ុន្មានទេ តែឌុចជាមេ ជាគោលនៅកន្លែង ហ្នឹង។

FL: អញ្ចឹងគាត់ជាមេ គាត់ធ្វើអ្វី?

បខ: គាត់សួរចម្លើយគេ ដូចថាគាត់វ៉ៃម៉ាហត់អញ្ចឹងគាត់ឱ្យគេសួរ ហើយគាត់នៅចាំស្តាប់ចម្លើយ។

FL: អញ្ចឹងក្រៅពីហ្នឹង តើលោកមានឃើញដោយផ្ទាល់ភ្នែកឌុចធ្វើទារុណកម្មអ្នកផ្សេងទេ?

បខ: ក្រោយៗម៉ោខ្ញុំមិនបានឃើញជាញឹកញាប់ទេ គ្រាន់តែម្តងម្កាល ដូចថាចូលម៉ោកន្លែងខ្ញុំវ៉ៃម៉ាដៃ ម៉ាជើងអីហ្នឹង ទៅកន្លែងផ្សេងៗអី អាណឹងម្តងម្កាលទេ។

FL: លោកហ្វ្រង់ស័រ ប៊ីស្សូត គាត់បានថតរឿងគុនមួយ ក្នុងនោះលោកធ្លាប់ថាឃើញឌុចហ្នឹងធ្វើទារុណកម្មអ្នកទោសហ្នឹងសើច?

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

បខ: ពេលធ្វើទារុណកម្មហ្នឹងគឺវ៉ៃបណ្តើសើចបណ្តើរ សើចសប្បាយជាមួយគ្នាគាត់ប៉ុន្មាននាក់ហ្នឹង។

FL: នៅក្នុងពេលណាដែរ?

បខ: ករណីជាមួយស្ត្រីម្នាក់ហ្នឹង។

សស: ពេលឌុចអត់នៅ តើអនុប្រធានមួយណាដែលឡើងជំនួសឌុចដើម្បីគ្រប់គ្រងស-២១?

បខ: ពេលឌុចមិននៅ ការគ្រប់គ្រងខ្ញុំឃើញតែហ៊ី អនុប្រធានមន្ទីរស-២១ហ្នឹង ប៉ុនខាងផ្នែកឯកសារ អីមិនដឹងដែរ

ក្រែងតាមផ្នែកៗវាមិនដឹង ខ្ញុំក្តាប់មិនបានដែរ។

សស: បងឃើញមានពេលឌុចអត់នៅស-២១យូរទេ ចុះទៅមូលដ្ឋានមួយខែ ឬមួយអាទិត្យអីមាន ដែលអញ្ចឹងទេ?

បខ: រឿងដើរចោលកន្លែងខ្ញុំមិនដែលឃើញដើរចោលទេ។

សស: ក្នុងការធ្វើទារុណកម្មនេះ តើឌុចមានដែលណែនាំថាធ្វើវិធីនេះវាមានប្រសិទ្ធិភាពអី ដោយសារ គាត់ធ្លាប់ប្រើនៅម-

១៣អីវាមានប្រសិទ្ធិភាពអី គាត់មានដែលប្រាប់រឿងម-១៣ឱ្យស្តាប់ទេ?

បខ: បើនិយាយពីរឿងម-១៣ដែលនៅអមលាំងនេះ កាលណាយកទៅរៀនសូត្រផ្នែកនយោបាយ អី

បច្ចេកទេសអីនៅផ្ទះគាត់ហ្នឹង មួយម៉ោងឬកន្លះម៉ោងភាគច្រើននិយាយពីម-១៣ហ្នឹងហ្មង ប៉ុនខ្ញុំ ភ្លេចអស់ហើយ។

ងអ: ការធ្វើទារុណកម្មលើអ្នកទោស តើក្នុងគោលបំណងយកចម្លើយសារភាពតែមួយគត់ ឬក៏មាន គោលបំណងផ្សេងទៀត?

បខ: ក្នុងការសួរចម្លើយខ្លាំង ធ្វើទារុណកម្មគឺក្នុងគោលបំណងយកចម្លើយតែមួយមុខគត់។

ងអ: ហើយ តើមានអ្នកទោសដែលទទួលទារុណកម្មហើយមិនមានចម្លើយសារភាពទេ?

បខ: ចំពោះអ្នកទោសដែលធ្វើទារុណកម្មហើយគឺពាក់កណ្តាលនៃការសួរមិនបានចម្លើយ។

ងអ: ហើយពេលដែលត្រូវបានធ្វើទារុណកម្មអ្នកខ្លះត្រូវរបួសអីហើយ តើស-២១មានចាត់ចែងពី

រឿងព្យាបាលអីយ៉ាងម៉េចទេពីរឿងអ្នកទោស?

បខ: ចំពោះអ្នកទោសដែលសួរចម្លើយហើយ របួសនៅពេលហ្នឹងគឺមានពេទ្យគេអ្នកដើរព្យាបាល កាលហ្នឹងពេទ្យសឿង

ប្រធានពេទ្យទ្រី ហើយស្តាយកាតាបមានលាងរបួស បិទរបួសអី។

ងអ: សឿងសព្វថ្ងៃនៅណាលោកមានដឹងទេ?

បខ: ឥឡូវមិនដឹងនៅរស់ឬស្លាប់ទេ នៅកំពង់ឆ្នាំង។

CB: អញ្ចឹងពេទ្យពីរនាក់ហ្នឹង ពេទ្យដដែលហ្នឹងដែលបូមឈាមពិនិត្យអ្នកទោសអី?

បខ: អ្នកយកឈាមយកអីហ្នឹងគឺពេទ្យទ្រីហ្នឹងហ្នឹង និងកូនចៅ នៅកន្លែងពេទ្យហ្នឹងជួនកាលម៉ោង ១០, ១១អី

កន្លែងពេទ្យនិងផ្ទះខ្ញុំនៅជាប់គ្នាហ្នឹង ទៅអ្នកទោសចង់ម៉ាឡានអី ដែលបូមឈាមអស់ ហើយមិនទាន់ស្លាប់ទេ នៅផ្តឹកៗ

ឈាមជំនាន់ហ្នឹងបូមយកទៅដាក់មន្ទីរពេទ្យ នៅជំនាន់ហ្នឹងមាន សង្គ្រាមជាមួយវៀតណាម ឈាមហ្នឹងយកទៅពេទ្យ១៧មេសា

និងពេទ្យមុនីវង្ស។

FL: លោកបាននិយាយថា អ្នករបួសត្រូវការឈាម តើអ្នករបួសហ្នឹងសង្គ្រាមជាមួយណា?

00146602



បខ: កាលហ្នឹងកាលជំនាន់៧៧, ៧៨អីហ្នឹង ប៉ុល ពតវៃចូលវៀតណាម ដល់តាយណិញ ឡុកនិញ អីហ្នឹង អញ្ចឹងអ្នករបួសហ្នឹងដឹកយកម៉ោភ្នំពេញ អ្នករបួសហ្នឹងត្រូវការឈាមច្រើន។

FL: លោកបាននិយាយពីតាយនិញ តើលោកអាចនិយាយឱ្យច្បាស់ជាងហ្នឹងទេ?

បខ: កន្លែងប៉ុល ពតវៃឡុកចូលទៅដល់តាយណិញ ឡុកនិញ បានបាក់ម៉ោវិញ បាក់ម៉ោរហូត ដល់៧៩ហ្នឹង។

FL: មានអ្នករបួសច្រើនទេ?

បខ: អ្នករបួសច្រើន អ្នកនៅកងពលជាមួយខ្ញុំហ្នឹង ដល់ពេលជួបគ្នា វាប្រាប់ថា អ្នករបួសច្រើន ដល់ពេលវៃដល់ឡុកនិញហ្នឹងគេព័ទ្ធពីក្រោយ ដល់ម៉ោបាក់ម៉ោ វៃបុកម៉ោវិញហ្នឹង បាក់រហូត។

ងអ: លោកដឹងថា អ្នកបូមឈាម ដែលគេបូមហើយហ្នឹងយ៉ាងម៉េចដែរ ស្លាប់ ឬរស់?

បខ: អ្នកបូមឈាមហ្នឹងតាមខ្ញុំដឹងខ្ញុំឃើញ នៅកន្លែងខ្ញុំហ្នឹង គឺយកអ្នកណាដែលសាច់ឈាមល្អ អត់ មានឈឺ អាណឹងយកម៉ោគេបូមឈាម គេមើលឈាមអីតាមក្បួនពេទ្យអីហ្នឹង ហើយការបូមហ្នឹងគឺ ម្នាក់៤-៥ថ្លោក អ្នកទោសហ្នឹងលែងដឹងខ្លួនហើយ នៅដង្ហើមថ្លឹកៗ ហើយបូមហើយដកទុយយោ ហើយ យកអ្នកទោសទៅគរទុកម្ដុំ។

ងអ: គាត់ស្លាប់ ឬរស់ បន្ទាប់ពីនោះម៉ោ? ហើយអ្នកទោសហ្នឹងគេសួរចម្លើយហើយឬអីយ៉ាងម៉េច ដែលគេ បូមឈាមហ្នឹង?

បខ: ចំពោះអ្នកទោសដែលបូមឈាមហើយ គឺដឹងតែនិយាយថាបូមហើយគរទុកម្ដុំមិនទាន់ដាច់ខ្យល់ ស្លាប់ទេ តែក្រោយម៉ោស្លាប់ តែក្រោយម៉ោមានឡានចូលម៉ោដឹកយកទៅជើងឯក អញ្ចឹងអ្នកដែល បូមឈាមនោះស្លាប់ទាំងអស់គ្នា ពេលនោះខ្ញុំឃើញអញ្ចឹងខ្ញុំមានការរន្ធត់ខ្លាំង ចំពោះរូបខ្ញុំពេលធ្វើ ទារុណកម្មខ្ញុំមិនសូវរន្ធត់ទេ តែការដែលបូមឈាមហ្នឹងគឺខ្ញុំរន្ធត់ពេក ខ្ញុំនៅចងចាំរហូតអត់ភ្លេចទេ អារឿងបញ្ហាហ្នឹង។

CB: អ្នកដែលបូមឈាមហ្នឹងច្រើនទេ?

បខ: ក្នុងរយៈម្ដងៗ២០-៣០នាក់ តែមិនជាអចិន្ត្រៃទេ ៤-៥ថ្ងៃម្ដង តាមស្ថានមិនក្រោមពាន់អ្នកទេ ៤-៥ថ្ងៃជាប្រចាំអញ្ចឹងហ្មង រាប់ខែរាប់ឆ្នាំ។

CB: ចង់បញ្ជាក់លោកថា តើបច្ចេកទេសក្នុងការបូមយកឈាមហ្នឹង គេបូមឈាមដើម្បីឱ្យស្លាប់តែ ម្ដង ហើយគេដាក់គរលើគ្នា អញ្ចឹងបានន័យថាគេបូមឈាមដើម្បីឱ្យងាប់តែម្ដង?

បខ: ក្នុងគោលបំណងគឺសម្លាប់ហ្មង ទី២គឺបានឈាម គោលបំណងគឺសម្លាប់ហ្មង។

CB: អញ្ចឹងជាបច្ចេកទេសមួយក្នុងការសម្លាប់មនុស្ស?

បខ: បាទ។ ពេទ្យទ្រីជាមនុស្សសាមញ្ញ ស្លូត គាត់ជាប្រធានពេទ្យ តែគាត់សាមញ្ញណាស់ តែចុង បញ្ចប់គាត់ត្រូវគេចាប់យកម៉ោដាក់គុកសម្លាប់ ម៉ោពី៧០៣ដូចខ្ញុំដែរ។

FL: តើពេលណាម៉ោដែលមានការបូមឈាមហ្នឹង?

បខ: បូមឈាមហ្នឹងខ្ញុំឃើញតាំងពី៧៦ម៉ោទល់ចុងបញ្ចប់ហ្នឹង។

FL: ដើមឆ្នាំ៧៦ អីក៏ចុង?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00146603



បខ: ក្នុងកំឡុង៧៦ តែមិនដឹងដើមឆ្នាំអីចុងឆ្នាំទេ ព្រោះផ្ទះគាត់និងខ្ញុំរបងជាប់គ្នា គ្រាន់តែឡើងទៅ លើហើយមើលម៉ោក្រោមហ្នឹងឃើញហើយ ព្រោះផ្ទះពេទ្យនោះផ្ទះឈើ ហើយជាក់ស្តែងខ្ញុំទៅ ឈរមើលហ្នុង រហូតដល់អស់ឈាមយកមនុស្សចេញ អញ្ចឹងបានខ្ញុំថាអណោចអធមណាស់។

FL: អញ្ចឹងអ្នកទោសដែលគេចាប់ម៉ោបូមឈាមហ្នឹង តើមុនហ្នឹងគេប្រាប់ថាមូលហេតុអីបានគេយក ម៉ោបូមឈាមហ្នឹងទេ?

បខ: អ្នកទោសដែលសួរចម្លើយហើយ ឬខ្លះគេអត់សួរចម្លើយទេ អញ្ចឹងមុនគេយកទៅកម្ទេច អញ្ចឹងគេ បូមយកឈាម។

FL: អ្នកណាប្រធាននៅអង្គភាពបូមឈាម? ហើយអង្គភាពឈ្មោះអី?

បខ: ពេទ្យទ្រីប្រធានពេទ្យនៅស-២១ហ្នឹងហ្នុង អត់មានថាអង្គភាពអីទេ អាណឹងពេទ្យប្រចាំនៅ ស-២១ហ្នឹង ប្រធានទ្រីហ្នឹងហ្នុង អាណឹងពេទ្យប្រចាំអង្គភាព ប្រចាំមន្ទីរ។

FL: តើអ្នកណាទទួលខុសត្រូវនៅមន្ទីរពេទ្យនៅស-២១ហ្នឹងហ្នុង?

បខ: ទ្រីហ្នឹងហើយ។

FL: ធំជាងទ្រី?

បខ: មានតែឌុចហ្នឹងហ្នុង។

FL: គាត់នៅក្រោមបញ្ជារបស់ឌុច?

បខ: បាទ!

FL: ធ្លាប់ឃើញឌុចទៅកន្លែងបូមឈាមទេ?

បខ: ខ្ញុំមិនដែលបានឃើញចូលផង ព្រោះពេលយប់។

FL: តើលោកដឹងថាអ្នកណាបញ្ជាឱ្យបូមឈាមហ្នឹង?

បខ: ខ្ញុំមិនដឹងច្បាស់ទេ បើតាមសន្និដ្ឋានរបស់ខ្ញុំបើឌុចមិនបញ្ជាទេគ្មាននរណាហ៊ានធ្វើទេ?

FL: អញ្ចឹងលោកធ្លាប់ឃើញនិសាររបស់ឌុចម៉ោកន្លែងពេទ្យហ្នឹងទេ?

បខ: និរសាចេញចូលគ្រប់កន្លែងទាំងអស់ហ្នឹង។

FL: អញ្ចឹងឈាមហ្នឹងណាគេម៉ោយក? ហើយបញ្ជូនទៅណាខ្លះ?

បខ: ខ្ញុំមិនបានឃើញណាម៉ោយកទៅទេ ប៉ុនមិនដឹងយកទៅណាទេ តែដឹងថាយកទៅ១៧ ឬមន្ទីរវង្ស

FL: តើគេមានធ្វើបញ្ជីថាឈាមហ្នឹងយកម៉ោពីអ្នកនេះ ហើយយកប៉ុន្មានទេ?

បខ: អត់មានទេ ជំនាន់ហ្នឹងអត់មានធ្វើបញ្ជីអីអត់ទេ។

FL: នៅពេលដែលបញ្ចប់ការសាកសួរចម្លើយហ្នឹង តើអ្នកណាសម្រេចថាយកគាត់ទៅបូមឈាម?

បខ: ខ្ញុំមិនបានដឹងទេខាងលើ គ្រាន់តែខ្ញុំគិតក្នុងចិត្តបើមិនប្រធានមន្ទីរឱ្យយកគ្មានណាហ៊ានយកទេ។

FL: ចុះចំពោះលោកស្គាល់លោកដែលបានធ្លាប់ឌុចបញ្ជាឱ្យយកអ្នកទោសទៅបូមឈាមទេ?

បខ: អត់ទេ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00146604

ងអ: ពេលបួមឈាមហ្នឹងអ្នកទោសហ្នឹងគេដាក់ខ្នោះដែរ?

បខ: ពេលអ្នកទោសយកម៉ោបួមឈាមហ្នឹងគឺយកពីក្នុងគុកម៉ោគឺដាក់ខ្នោះដៃទៅក្រោយ ចងមុខ ហើយម៉ោដល់គ្រែបួមហ្នឹង ដោះខ្នោះដៃ ចងដៃនឹងប្រង់ការ បិទមុខ ចងជើង។

សស: បងមានដែលឃើញអ្នកទោសជាពិសេសអ្នកទោសជនជាតិភាគតិចមានដែលឃើញម៉ោសួរម៉ាថ្ងៃពីរ ថ្ងៃអីម៉ោសួរហើយ ប្រលែងទៅស្រុកវិញទេ?

បខ: ចំពោះអ្នកទោសដែលចូលទៅស-២១ខ្ញុំមិនដែលឃើញចេញទៅវិញទេ។

សស: មិញនិយាយពីរឿងនិរសាខុចដែលឃើញកន្លែងបួមឈាមហ្នឹងដែរ តើបងមានដឹងថាមាន ឈ្មោះអីដែរ? នៅរស់អីដែរ?

បខ: និរសាខុចហ្នឹងកាលមុនស្គាល់ តែឥឡូវភ្លេចអស់ហើយ នឹកឈ្មោះអត់ឃើញ។

ងអ: ខាងបួមឈាមមានតែពីរនាក់ហ្នឹងទេ?

បខ: ពេទ្យបួមឈាមមែនមានពីរទេ តែតាមខ្ញុំចាំច្បាស់តែពីរហ្នឹងទេ ប៉ុន្តពេទ្យមានមិនច្រើនទេ មាន៤-៥នាក់ប៉ុណ្ណឹងទេ។

សម្រាកកិច្ចសម្ភាសន៍នៅម៉ោងដប់ពីរថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល។

ចាប់ផ្តើមកិច្ចសម្ភាសន៍នៅម៉ោងមួយនិងដប់ប្រាំនាទីថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល។

សស: ខ្ញុំសុំសួរថា អ្នកទោសដែលជាកម្មាភិបាលនៅស-២១ ដែលត្រូវបានចាប់ខ្លួនដាក់កន្លែងខ្លួនឯង វិញហ្នឹង ភាគច្រើនជាអ្នកមានប្រវត្តិម៉ោពីខាងណា? ហើយមានចំនួនប្រហែលជាប៉ុន្មានរយនាក់ដែរ ដែលចាប់ហើយសម្លាប់?

បខ: ចំពោះអ្នកទោសដែលចាប់ម៉ោដាក់នៅស-២១ ទួលស្លែងហ្នឹង អ្នកធ្វើការនៅហ្នឹងទាំងផ្នែកសួរ ទាំងផ្នែកការពារប្រភពដើមម៉ោពី៧០៣ទាំងអស់តាំងពីដំបូង អញ្ចឹងតាមខ្ញុំស្មានទៅប្រហែលជា ៣០០នាក់ មិនក្រោមពី៣០០នាក់ទេ ទាំងកងការពារ និងសួរចម្លើយ។ អញ្ចឹងអ្នក៧០៣បើតាមខ្ញុំ ដឹងសឹងតែទាំងអស់ នៅសល់តិចតួចទេ។

FL: ត្រូវចាប់ហើយសម្លាប់ទេ?

បខ: ចាប់ហើយសម្លាប់ទាំងអស់។

សស: អ្នកដែលជំនួសអ្នកដែលចាប់ទៅហ្នឹងច្រើនអ្នកមានប្រវត្តិម៉ោពីខាងណា?

បខ: អ្នកយកម៉ោជំនួសថ្មីហ្នឹងច្រើនម៉ោពីបស្ចឹម ខុចយកម៉ោផ្ទាល់។

សស: ទាំងកម្លាំងថ្មីដែលយកម៉ោពីបស្ចឹម ទាំងមនុស្សដែលត្រូវសម្លាប់ ៧០៣ដែលសម្លាប់មិញហ្នឹង ព្រឹត្តិការណ៍ទាំងពីរហ្នឹងខុចជាអ្នកសម្រេចក្នុងការចាប់៧០៣ ហើយយកបស្ចឹមម៉ោច្រើនអញ្ចឹង ឬក៏ មានបញ្ហាម៉ោពីខាងលើ?

បខ: កម្លាំងដែលយកម៉ោប្តូរទាំងអស់ហ្នឹង បើតាមខ្ញុំស្មាន ប្រហែលជាខុចហ្នឹងសុំយោបល់ពីខាង លើម៉ោបាន១យកម៉ោដាក់កន្លែងហ្នឹងវិញ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

សសៈ បងថា ប្រហែលជាសុំយោបល់ខាងលើហ្នឹង ប្រហែលជាសុំពីណា?

បខៈ ប្រហែលជាសុំម៉ោតាម ខ្ញុំស្មានទេ ព្រោះឌុចច្រើនតែនិយាយពីរឿងបងទីមួយ និងទី២ អញ្ចឹងមានតែសាឡុត ស បងទី១ នួន ជា បងទី២។

សសៈ នេះប្រហែលជានៅឆ្នាំណាដែរ?

បខៈ ព្រឹត្តិការណ៍ហ្នឹងកើតឡើងនៅឆ្នាំ១៩៧៨។

សសៈ បងដឹងថា កាលដែលសម្រេចសម្លាប់៧០៣ មុនយកបស្ចឹមម៉ោហ្នឹង តើការសម្រេចហ្នឹងម៉ោ ពីថ្នាក់លើឈ្មោះអីដែលសម្រេចឱ្យសម្លាប់៧០៣ច្រើនអីចឹង ឬមួយឌុចសម្រេចខ្លួនឯង?

បខៈ រឿងនេះខ្ញុំមិនអាចសន្និដ្ឋានថា ឌុចឱ្យសម្លាប់ខ្លួនឯង ព្រោះខ្ញុំនៅខាងក្រោមមិនអាចដឹងអស់។

FL: ឌុចគាត់ម៉ោពីខាងបស្ចឹម ហើយហ៊ីម៉ោពីខាង៧០៣ តើទំនាក់ទំនងពីរនាក់ហ្នឹងយ៉ាងម៉េចដែរ?

បខៈ ជាដំបូងខ្ញុំម៉ោនៅហ្នឹងមិនដែលឃើញមានអីកើតឡើង ព្រោះហ៊ីគាត់អនុប្រធាន ដូចថាម៉ាផ្នែក ទៅដូចខាងសេដ្ឋកិច្ច កងការពារក្រៅក្នុង ឌុចគេក្តាប់រួម ប៉ុន្តែគេគ្រប់គ្រងខាងផ្នែកសួរចម្លើយ ផ្នែក ក្នុងគុក អញ្ចឹងរឿងការទំនាស់ទាស់តែងគ្នាមិនដែលឃើញ ប៉ុនថាចេះសម្គាល់ឃើញលក្ខណៈរស់នៅ គឺកម្លាំង៧០៣រិចរិលទៅៗ ចាប់បន្តបន្ទាប់ កម្លាំង៧០៣ដែលធ្វើនៅស-២១ហ្នឹង ហើយកម្លាំងបស្ចឹម យកម៉ោបន្តបន្ទាប់ ម្នាក់ៗមានការរំជើបរំជួលចិត្ត ម្នាក់ៗរង់ចាំតែសភាពការណ៍ហ្នឹងទេ ពេលរណសិរ្សរំដោះបានហ្នឹងគឺមានការត្រេតអរខ្លាំងណាស់ ព្រោះថ្ងៃមួយខ្ញុំភ័យខ្លាំងមែនទែន ប្រហែលជាម៉ោង២យប់គេម៉ោហៅ ឈ្មោះផលកងការពារដែរ គេថា ខន អ្អែងម៉ោនេះម៉ោ ខ្ញុំភ្ញាក់ ឡើងភ័យណាស់ នឹកថាគេចាប់ហើយ តោះទៅស្តាប់លលកខ្មោចនៅជិតវត្តមហាមន្ត្រីជាមួយអញ ព្រោះសភាពការតានតឹងណាស់ ពេលហ្នឹងខ្ញុំភ័យអស់ព្រលឹងព្រលះអស់រលីងហើយ។

សសៈ តាមការសម្គាល់របស់បងជាអ្នកសួរចម្លើយ ឬតាមការជជែកជាមួយកម្មាភិបាលដែលជាអ្នក សួរចម្លើយដែរហ្នឹង តើការដែលចាប់៧០៣ហ្នឹងដោយសារឌុចមានការថ្នាំងថ្នាក់ ឬក៏ភ័យខ្លាច៧០៣ ហ្នឹងគ្របពីលើឡើងកាន់ដំណែងរបស់ខ្លួនឯង ឬយ៉ាងណា? អានេះតាមការយល់ឃើញរបស់បងផ្ទាល់

បខៈ បញ្ហានេះខ្ញុំគ្រាន់តែថា រឿងកម្លាំង៧០៣កាលហ្នឹងម៉ោដំបូងនៅស-២១ហ្នឹងគឺសុទ្ធសឹង៧០៣ ទាំងអស់ តាំងពីប្តូរប៉េស៊ីទៅស-២១ហ្នឹង ដល់អញ្ចឹងកម្លាំងកាលហ្នឹងសុទ្ធតែកម្លាំងពិសេសរបស់ ៧០៣ទាំង ដូច តាម៉ាន ផេង ទុយ ប៊ូ ដែលយើងសុំពីកងពិសេស៧០៣ម៉ោគ្រប់គ្រង កម្លាំងតូចៗ ហ្នឹង ក៏ជាកម្លាំង៧០៣ អញ្ចឹងតាមការប៉ានស្មានហ្នឹង ឌុចហ្នឹងគាត់មិនចង់ឱ្យកម្លាំង៧០៣ គ្រប់គ្រង ទាំងអស់មិនដឹង ឬក៏តាមចាប់ខ្សែរយៈ៧០៣ទាំងអស់មិនដឹង អញ្ចឹងអ្នកដែលមានប្រវត្តិនៅ កងពល១២, ៧០៣ពីមុនហ្នឹងមានការពុះកញ្ជ្រោលទាំងអស់ អញ្ចឹងតាមការសន្និដ្ឋានរបស់ខ្ញុំមើល ទៅប្រហែលជាមិនឱ្យកងពល៧០៣ឡើងកាន់អំណាច ខ្លាចគាត់មិនបានធ្វើជាប្រធានរហូត។

សសៈ ក្នុងនាមបងជាអ្នកសួរចម្លើយប្រហែលជាអាចដឹងច្បាស់ជាងគេ គឺថា ពេលវេលាដំបូងដែល កម្លាំង៧០៣ត្រូវបានចាប់ម៉ោដាក់នៅស-២១ហ្នឹង តើនៅពេលណា បើមិនចាំខែទេ នៅដើមឆ្នាំ ឬ ក៏ចុងឆ្នាំណា? តើកម្លាំង៧០៣ឆ្លើយដាក់គ្នាបានចាប់ច្រើន



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ឬក៏ដោយសារអីផ្សេងបើតាមការសម្គាល់ មើលចម្លើយសារភាពសួរដោយខ្លួនឯង?

បខ: កាលពីក្នុង៧៧, ៧៨ហ្នឹង ៧៥, ៧៦ហ្នឹងមានព្រឹត្តិការណ៍មានការចាប់ហ៊ូ នឹម ហ៊ូ យន់ តាណាត តាពីន ចាន់ចក្រី ពេលហ្នឹង សភាពការណ៍ហ្នឹងផ្ទុះនៅភ្នំពេញ ដោយសារចាប់មេៗអស់ ថ្នាក់ក្រោម ហ្នឹងខ្លះរត់ទៅវៀតណាម ខ្លះចាប់បានយកម៉ោដាក់ស-២១ហ្នឹង ចេះតែឆ្លើយដាក់គ្នាបន្តបន្ទាប់ហ្នឹង អ្នកតូចឆ្លើយដាក់អ្នកធំហ្នឹង តាណាត៧០៣ហ្នឹង ចាន់ចក្រីខាងបូព៌ាហ្នឹង ចេះតែឆ្លើយដាក់បន្តបន្ទាប់ ហ្នឹង អញ្ចឹងខាង៧០៣ហ្នឹងចាប់តាមខែបណ្តោយពីលើម៉ោក្រោម។

សស: អញ្ចឹងបានន័យថា មានព្រឹត្តិការណ៍ហ្នឹងកើតឡើងហើយក្នុងហ្នឹងមានចាប់មេៗ៧០៣ផង ក្រោយម៉ោបានមានចាប់៧០៣ឱ្យកាន់តែច្រើនឡើង?

បខ: បាទ!

FL: អញ្ចឹងលោកនិយាយថា មុនចាប់មេដឹកនាំហ្នឹង អាព្រឹត្តការណ៍ហ្នឹងកើត៧៧, ៧៨ តើមុនឆ្នាំ៧៦ ហ្នឹងតើអ្នកណាដែលគេចាត់ថាសត្រូវ ជាខ្មាំង?

បខ: តាំងពី៧៥, ៧៦ម៉ោហ្នឹង អាណឹងមានចាប់ដែរ តែតិចតួច ចាប់អ្នកតូចៗ អ្នកធ្វើការតែមិនមាន ចាប់ដល់ថ្នាក់កងពល ថ្នាក់តំបន់ ឬក៏ថ្នាក់ក្នុងលេខាបក្សអីទេ ទាល់តែចុង៧៧អីណោះ។

FL: តើព្រឹត្តិការណ៍ហ្នឹងមានលក្ខណៈរួមទេ តើការចាប់អ្នកដែលធ្វើការនៅខាងក្នុងជាមួយខ្លួនហ្នឹង នៅកន្លែងផ្សេងទៀតដូចនៅស-២១ហ្នឹងទេ?

បខ: អាការចាប់ផ្ទៃក្នុងហ្នឹងគឺមានកើតឡើងគ្រប់កន្លែងទាំងអស់ទូទាំងប្រទេស។

សស: បងដែលបានធ្លាប់យកចម្លើយសារភាពទៅឱ្យឌុច ហើយឌុចចារម៉ោវិញហ្នឹង តើបងមានចាំខ្លះ ទេ បើឱ្យបងមើលបងអាចដឹងទេ?

បខ: ស៊ីញ៉េរបស់ឌុចគឺខ្ញុំចាំបាន។

សស: អញ្ចឹងបងមើលអានេះ អក្សរឌុចអីក៏មែនទេ?

បខ: ហ្នឹងហើយក្រោម ស៊ីញ៉េឌុច។

សស: នេះជាចំណាររបស់ឌុច ដែលគូសចោលអក្សររបស់ណៃ សារ៉ានហៅយ៉ា ជាមេដឹកនាំភូមិភាគ ឥសាន យ៉ាឆ្លើយថា គាត់ឆ្លើយនៅពេលដែលធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ ហើយឌុច គូសពាក្យធ្វើ ទារុណកម្មហ្នឹងចោល រួចសរសេរថា បងយ៉ាងឯងគ្មានសិទ្ធិវាយការណ៍លើបញ្ហា ហ្នឹងទេ ខ្ញុំបានមាន សិទ្ធិវាយការណ៍ កុំលែងស្អាតចង់បដិសេធមិនបានទេ។

FL: អញ្ចឹងលោកអាចស្គាល់ស៊ីញ៉េហ្នឹងជាស៊ីញ៉េរបស់អ្នកណា?

បខ: ស៊ីញ៉េ ឌុច។

FL: តើឯកសារហ្នឹងឯកសារអីគេឮដឹងទេ (ឌី៧៣៥៨)?

ងអ: ខ្ញុំសួរបញ្ជាក់ថាអានេះគឺឯកសារមួយដែលមានចំណារ តែអត់មានហត្ថលេខាទេ តែខ្ញុំចង់ដឹងថា អក្សរនេះរបស់ពីណា (ស្នើសួរប្អូនក្រៅពីនេះវាយចោល។)



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00146607

ការស/NC DAS/VIII

បខ: អក្សររបស់ឌុច។

FL: តើឯកសារហ្នឹងឯកសារអីគេពូដឹងទេ (D៧៣៥៨ ERN 00007270)?

បខ: ឯកសារវាយឈ្មោះដែលត្រូវចាប់ខ្សែបណ្ដាញ។

ងអ: ឯកសារនេះថា (ស្នើសួរបួនាក់ ក្រៅពីនេះវាយចោល) តែមិនមានហត្ថលេខាទេ តើចំណារ របស់ពីណា?

បខ: ពាក្យហ្នឹង អក្សរហ្នឹង ហើយសម្ដីហ្នឹងគឺចេញពីឌុចហ្នឹងហ្មង។

សស: ស៊ីញ៉េហ៊ុយនេះ ហ៊ុយណា (D៧៣៥៨ ERN 00007270)?

បខ: អត់ដែលឮ។

សស: តែហ៊ុយនេះ ហ៊ុយស្រែអីក៏ហ៊ុយតូចអ្នកធ្វើបញ្ជី?

បខ: បើហ៊ឹម ហ៊ុយនេះ អត់ទេ។

សស: អញ្ចឹងបងអត់ស្គាល់ឈ្មោះនៅលើហ្នឹងទេ?

បខ: អត់ ឈ្មោះហ្នឹងប្លែកៗហ្មង។

CB: ពូថាប្រហែលជាហ៊ុយស្រែ ពូអត់ស្គាល់ឈ្មោះនៅក្នុងហ្នឹងទេ?

បខ: បើសិនជាហ៊ឹម ហ៊ុយ ខ្ញុំអាចស្គាល់ឈ្មោះហ្នឹងហើយ។

ងអ: ទាក់ទងនិងការចាប់អ្នកស-២១ដែលម៉ោពី៧០៣ហ្នឹង តើការដែលចាប់ហើយ ហើយបញ្ជូនទៅ ឱ្យអ្នកណាសួរចម្លើយទៅវិញ បើអ្នកកងពល៧០៣សួរចម្លើយនៅហ្នឹងដែរ?

បខ: ក្នុងហ្នឹងគឺឃើញយកទៅសួរចម្លើយច្រើនចាន់ ប៊ុន ម៉េង ជួនកាលឌុចអ្នកសួរ ប៊ុនចាន់អី ឌុចជួយ សួរម៉ាសំណួរហើយដើរចេញទៅ តែអចិន្ត្រៃយ៍ចាន់ ប៉ុន្ដែអត់សួរជាមួយអ្នកសួរចម្លើយទេ គឺផ្សេង តែ កាលចេញពីបន្ទប់សួរចម្លើយម៉ោគឺយកភួយគ្របជិតទាំងអស់ ឃើញតែជើងទេ អាណើងគឺផ្ទៃក្នុង។

ងអ: អញ្ចឹងបញ្ជាក់ថា កម្មាភិបាលយុទ្ធជនស-២១ ដែលចេញពី៧០៣ហ្នឹងគឺមិនមានខាង៧០៣ជា អ្នកសួរទេ?

បខ: អាត្រង់ហ្នឹងគឺមិនឱ្យកម្លាំង៧០៣សួរទេ គឺគេឱ្យកម្លាំងផ្សេងទៀតហ្នឹងសួរ។

ងអ: ខ្ញុំគ្រាន់តែសុំឱ្យលោករំលឹកវិញមើលអស់ប៉ុន្មានដែរ អ្នកដែលចាប់នៅស-២១ហ្នឹង?

បខ: ខ្ញុំមិនអាចថាត្រូវទេ ព្រោះវាមិនដឹង ប្រហែលក្នុងស-២១ហ្នឹងបើចំនួននៅក្នុងស-២១ទាំងកង ការពារទាំងសួរចម្លើយ ខ្ញុំប៉ាន់ស្មានប្រហែលជា៣០០នាក់ បើសល់យ៉ាងច្រើនបំផុត៥០-៦០នាក់ ខ្ញុំ ឃើញសល់កន្លែងកងការពារហ្នឹងឃើញសល់ច្រើន ក្រៅពីហ្នឹងបើនៅកន្លែងសួរចម្លើយហ្នឹងគឺអត់មាន សល់សុទ្ធ សល់តែខ្ញុំទេដែលម៉ោពី៧០៣។

ងអ: អញ្ចឹងទាក់ទងនិងការចាប់ ពីណាអ្នកទៅចាប់ បើកម្លាំងការពារសុទ្ធតែ៧០៣ដែរ?

បខ: កម្លាំងចាប់កាលនោះខ្ញុំអាចដឹងខ្លះៗតាមរយៈមិត្តដែលនៅជាមួយគ្នាហ្នឹងគឺមានហ៊ុយ មានប៉េង មានប៊ូ ដែលជាអ្នកដៃដល់ហ្នឹង។

ងអ: ចាប់គ្នាឯងហ្នឹង?

បខ: បាទ!

ងអ: អំពីអ្នកទោសនៅស-២១ដែលសម្លាប់ បូកសរុបប៉ានស្មានមើល ដែលលោកធ្លាប់ធ្វើការ នៅហ្នឹង ប្រហែលជាចំនួនប៉ុន្មានអ្នកទោសទាំងអស់?

បខ: ខ្ញុំមិនអាចសន្និដ្ឋានបានទាំងអស់ទេ ព្រោះមានចេញចូលៗជាបន្តបន្ទាប់ តែវាអត់ក្រោមពីរាប់ ម៉ឺននាក់ទេ។

ងអ: ហើយមួយទៀតទាក់ទងនិងការដែល ពេលដែលវៀតណាមចូលម៉ោ ខាងក្រុមស-២១នាំគ្នាចេញនៅក្នុងថ្ងៃណាលោកមានបានដឹងច្បាស់ទេ?

បខ: នៅពេលវៀតណាមចូលមុនចូលមួយថ្ងៃ អញ្ចឹងនៅក្នុងស-២១ហ្នឹង មុនចូលម៉ាថ្ងៃគឺបិទទ្វារ ទាំងអស់ ដឹងសភាពការណ៍ឮស្នូរកាំភ្លើងផ្ទុះនៅអ្នកលឿង ។

CB: អញ្ចឹងថ្ងៃប៉ុន្មាន ដែលបិទមុនម៉ាថ្ងៃ?

បខ: ថ្ងៃវៀតណាមចូលថ្ងៃទី៧មករា អញ្ចឹង៦មករា បិទជិត ព្រោះសភាពការណ៍មុនថ្ងៃ៦, ៥, ៣, ៤ តាំងពីថ្ងៃ២, ៣ទៅសភាពការណ៍ដែលជ្រួលច្របល់ឮស្នូរកាំភ្លើងហ្នឹងនៅជិតអ្នកលឿងហ្នឹង អញ្ចឹង សភាពការណ៍នៅស-២១ហ្នឹងអ្នកទោសទាំងអស់គឺបោសសម្អាត ដឹកចេញទៅអស់។

ងអ: អញ្ចឹងអ្នកទោសឃើញមានស្លាប់នៅកន្លែងស្នួរចម្លើយនៅអាគារអា ហ្នឹងតើលោកដឹងទេថា តើអ្នកណាជាអ្នកបញ្ជាឱ្យសម្លាប់?

បខ: ខ្ញុំមិនបានចូលទៅឃើញអ្នកទោសនៅអាគារអាទេ ប៉ុនអាគារអាដាក់តែអ្នកមានឋានៈធំៗ អញ្ចឹង មុន៧មករាដែលមុនចូលដល់ភ្នំពេញហ្នឹង អ្នកទោសហ្នឹងគឺត្រូវកម្ទេចនៅហ្នឹង ខ្ញុំគេឱ្យត្រៀម កាន់កាំភ្លើងនៅល្វេទឹកស្អុយខាងកើតឃើញរថក្រោះអីនៅខាងផ្លូវមុន្នីវង្សហ្នឹង បាននាំគ្នាដក បានម៉ោនៅព្រៃអំពៅដល់យប់ ដល់យប់បានឆ្លងទៅចំការដូង ទៅព្រៃសឡើងទៅភ្លើងឆេះរទេះ ទៅ អមលាំងទៅអី។

FL: មុនទ័ពវៀតណាមចូលម៉ោដល់ ពូមានដឹងថាអ្នកណាដែលធំនៅស-២១ហ្នឹងទេ?

បខ: មុនចូលទៅហ្នឹង និយាយរួមអ្នកដែលមានឋានៈធំៗហ្នឹងកម្ទេចអស់ហើយ។

FL: មុនវៀតណាមចូលម៉ោដល់មានអ្នកធំៗចូលម៉ោប្រាប់ស-២១ទេ?

បខ: អត់ដែលឃើញសុទ្ធ។

FL: អញ្ចឹងមុនទ័ពវៀតណាមម៉ោដល់ លោកមានដែលទទួលសេចក្តីណែនាំអី ឬបញ្ជាពិសេសអីពី ថ្នាក់លើម៉ោទេ?

បខ: មុនវៀតណាមចូលម៉ោហ្នឹងគឺគេអត់មានណែនាំអីក្រៅពីបើកអាវុធឱ្យ និងការពារនៅល្វេទឹក ស្អុយតែការពារកាលនោះអត់មានអីទេ មានតែអ្នកនៅឃោសនាការអីៗហ្នឹងប្រមូលគ្នាម៉ោទាំង អស់ហ្នឹង។

FL: ទាក់ទងនិងការចែកកាំភ្លើង តើមានអ្នកនៅក្នុងធ្វើការហ្នឹងយកកាំភ្លើងហ្នឹងម៉ោការពារ ឬក៏ឌុច ហ្នឹងបញ្ជាម៉ោ?

បខ: ឱ្យទៅយកកាំភ្លើងហ្នឹងគឺមានបទបញ្ជាម៉ោពីហ៊ី ឱ្យទៅយកកាំភ្លើងម៉ោពីឃ្លាំងហ្នឹងយកម៉ោកាន់ គ្រប់ដៃ។

FL: នៅថ្ងៃណា?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FL

00146609



បខ: នៅថ្ងៃ៧មករាហ្នឹងហ្នង ពេលព្រឹក ប៉ុនអាវុធឱ្យកាលហ្នឹងសុទ្ធតែអាវុធចាស់ៗ កាប៊ី អ៊ឹមសី សេកាសេ អត់មានអាការទេ។

CB: កបាននិយាយនៅថ្ងៃទី១២ ខែ១០ឆ្នាំ២០០៦ ជាមួយព្រះរាជអាជ្ញាថាមានការកាប់សម្លាប់ យ៉ាងព្រៃផ្សៃទៅលើកូនក្មេង កូនក្មេងគេយកទៅជាន់ទីបីហើយបោះម៉ោខាងក្រោម ឱ្យបាក់ក តើ អាណឹងជាការពិតទេ? តើលោកបានចូលរួមព្រឹត្តិការណ៍ហ្នឹងទេ?

បខ: ព្រឹត្តិការណ៍ហ្នឹងជាក់ស្តែងហ្នឹងហ្នង ពេលហ្នឹងចាប់វៀតណាមទាំងប្តីប្រពន្ធ ទាំងកូនហ្នឹង កូនហ្នឹងប្រហែលជា ៥, ៦ខែ ពេលគេចាប់ឪពុកម្តាយទៅក្នុងបន្ទប់ កូនហ្នឹងគេទុកនៅក្រៅ កាលហ្នឹង ដែក ប៊ូលើកទម្លាក់យកម៉ោក្រោម ងាប់បាត់ ឱ្យខ្ញុំយកទៅកប់។

ងអ: ហើយប៉ុន្មាននាក់?

បខ: ខ្ញុំឃើញតែម្នាក់ទេ។

FL: តើលោកថាពីការចាប់ប្រជាជនវៀតណាមហ្នឹងពេលណា?

បខ: វាមិនចាំទេ តាំងពីខ្ញុំចូលដំបូងនៅកងការពារណោះ មិនទាន់ចូលស្នួរចម្លើយ។

FL: អញ្ចឹងបានន័យថាគេមានបញ្ជាខាងលើឱ្យទៅចាប់ប្រជាជនវៀតណាម?

បខ: មិនដឹងជាបញ្ជាយ៉ាងម៉េចទេ តែតាមខ្ញុំភ្លាប់ទៅ ប្រជាជនវៀតណាមចូលម៉ោកម្ពុជា កម្ពុជា វៀតណាមមានទំនាស់គ្នា ក្រោយកម្ពុជាប្រជាធិបតេយ្យមានជ័យជម្នះ១៧មេសា វៀតណាម៣០ មេសា ក្រោយជិតម៉ាខែ ដល់ក្រោយម៉ោមានទំនាស់រឿងបក្ស អញ្ចឹងប្រជាជនចូលម៉ោកម្ពុជាៗចាប់ ចូលខាងវៀតណាមៗចាប់ កាលហ្នឹងខាងប៉ុល ពតហ្នឹង ចង់គាស់រំលើងយកទឹកដីកូសាំងស៊ីន។

FL: អញ្ចឹងនៅពេលសាកស្នួរចម្លើយបានបញ្ចប់ ហើយពុំមានការចារអីពីខាងឌុចហ្នឹងទៀត អញ្ចឹង អ្នកទោសហ្នឹងត្រូវគេបញ្ជូនទៅជើងឯកដើម្បីសម្លាប់ចោល តើលោកធ្លាប់ទៅជើងឯកទេ?

បខ: ខ្ញុំមិនដែលបានទៅទេ ខ្ញុំទើបតែស្គាល់នៅឆ្នាំទៅនេះទេ។

ងអ: ក្នុងចំណោមអ្នកស្នួរចម្លើយទាំងអស់ ក្រុមក្តៅ ត្រជាក់ អង្គាម មានអ្នកណានៅរស់? ខ្ញុំអាន ឡើងវិញ ព្រោះលោកឆ្លើយរួចហើយ មានដែក ប៊ូ , ម៉េង ចាន់នៅក្រុមក្តៅ ក្រុមត្រជាក់មាន ជន ហើយនិងឡាច មៀន, ហើយក្រុមអង្គាម មានទិតជាប្រធាន តើប៉ុន្មាននាក់នោះមាននៅរស់ទេ?

បខ: នៅរស់តែខ្ញុំហើយនិងឡាច មៀន។

CB: ទាក់ទងទៅនឹងអ្នកដែលនៅរស់ លោកបាននិយាយពីឈ្មោះពៅ ដឹងនៅរស់ទេ?

បខ: នៅរស់ នៅកំពង់ឆ្នាំង។

សស: ពេលថ្ងៃចុងក្រោយដឹកអ្នកទោសយកទៅសម្លាប់ហ្នឹង ឌុចនៅបញ្ជាដែរ អីក៏រត់ទៅហើយ?

បខ: នៅពេលនោះសភាពការណ៍ផ្ទុះឡើងតាមព្រំដែនដល់ពេលដឹកជញ្ជូនអ្នកទោសយកទៅសម្លាប់ ចោលហ្នឹង តាំងពីថ្ងៃ៤, ៥,



FL

៦ហ្នឹង វាអត់មានការងារធ្វើទំនេរហើយ ដល់អញ្ចឹងចេះតែដើរចេញចូលៗ ក្បែរគុកហ្នឹង ដល់អញ្ចឹងឃើញនាំអ្នកទោសម៉ាហ្នឹងមានហ៊ី ប៉េង ហ៊ុយ ហ្នឹង ចាត់ចែង ជួនកាលមាន ឌុចដែរ ម៉ាយប៉ុៗហ្នឹងគគ្រឹកគគ្រេងមិនដឹងប៉ុន្មានសារទេ។

FL: ប្រហែលជាយើងត្រូវសួរលោកម៉ាចំនួនទៀត តើលោកយល់ព្រមមកម្តងទៀតទេ?

បខ: ពេលណា?

FL: ប្រហែលជាពីរ បីអាទិត្យទៀត អត់ទាន់ដឹង បន្ទាប់ពីច្រូតកាត់ហើយ។

បខ: អាចម៉ោបាន។

ងអ: សុំពេលក្រោយគឺសុំលោកមានការសហការណ៍ជាមួយយើងខ្ញុំបន្តទៀត មិនអាចបញ្ចប់ប៉ុណ្ណឹង ទេ កិច្ចការតុលាការមិនអាចបញ្ចប់ប៉ុណ្ណឹងទេ ត្រូវការលោកសហការណ៍។

បខ: ខ្ញុំគ្រាន់តែចង់អញ្ជេះ ក្នុងការសហការណ៍ហ្នឹង ឧទាហរណ៍ថា ខ្ញុំមានបញ្ហាអីមួយលើរូបខ្ញុំ មាន គេចង់ស្លាប់ ធ្វើបាបអី អាណឹងសុំជួយខ្ញុំផង។

FL: តើមានដែលរឿងហ្នឹងកើតឡើងទៅ?

បខ: មិនទាន់មានទេ។

ងអ: មានអ្វីលោកចង់បង្ហាញពីស-២១ហ្នឹងផ្សេងទៀតទេ?

បខ: ខ្ញុំដូចជាអស់ហើយ ខ្ញុំដែលចង់បង្ហាញហ្នឹងបានសួរអស់ហើយ ប្រាប់អស់ហើយ។

បញ្ចប់ការសម្ភាសន៍នៅម៉ោងបីនិងសែសិបប្រាំបួននាទីរសៀល ថ្ងៃខែឆ្នាំដដែល។

☒ ឯកសារថតចម្លងនៃកំណត់ហេតុមួយច្បាប់ត្រូវបានប្រគល់ឲ្យសាក្សីនេះ។

☒ អានឲ្យស្តាប់ហើយ សាក្សី មិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា។

☐ អានឲ្យស្តាប់ហើយ សាក្សី មិនព្រមចុះហត្ថលេខាទេ។

| សាក្សី<br>Witness<br>Témoin | អ្នកបកប្រែ<br>Interpreter<br>Interprète | អ្នកស៊ើបអង្កេត<br>Investigators<br>Enquêteurs |
|---|---|---|

Fabienne Luco



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boîte postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ឈ្មោះទីផលក្រុងទី៤ក

គ្រួសាររបស់ អាឡុខ និង ភារ៉ាម៉ ណង់

| ល.រ | ឈ្មោះដើម | ប.ខ | អាយុ | នាទី | ភេទ | ថ្ងៃចូល ប.ខ | អ្នកនាំចូល | ថ្ងៃចូលមក អ.ភ | អតីតកងចល័ត | កងថ្មី | ព្រឹត្តិការណ៍ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ស៊ិន កុំ | | ៤៥ | | ប្រុស | ១៧.៥.៧៥ | ខុត | ១១.៣.៧៧ | ស្ទឹងជីវ | ១៣ | [illegible] |
| ២ | សេង លង្កាត | | - | ព.រី | ស្រី | -៨- | - | - | - | ម.២ | [illegible] |
| ៣ | ស៊ិន សីលា | ចាន់ | ២២ | ទេពពូក | ប្រុស | ៥.៧០ | [illegible] | - | អគ្គីសនី | ១៣ | |
| ៤ | ស៊ិន រិទ្ធីរាខុត | ថា | ១៥ | - | - | ២.[illegible].៧១ | សុខ | ១១.៣.៦៧ | អគ្គីសនី | ១៣ | |
| ៥ | ស៊ិន ស្ដាបនា | ផុន | ១២ | ព.ជ | ប្រុស | ៥.៧៥ | ខុត | - | អគ្គីសនី ទី ២ | ១៣ | |
| ៦ | ស៊ិន សុចិត្រា | ឈួន | ១៥ | ព.ជ | - | ៧៥ | ខុត | ១១.៣.៧៧ | ទន្លានទឹក | ១៣ | |
| ៧ | ស៊ិន លក្ខិណា | | ៦ | ព.រី | ស្រី | ៧៥ | | - | នៅជាមួយម្ដាយ | ម.២ | |
| ៨ | ស៊ិន ទារា | | ៤ | - | - | ៧៥ | | ១១.៣.៧៧ | - | - | |
| ៩ | ទីម៉ ចាន់មុន្នី | ណាន | ២០ | ព.រី | ស្រី | ៧៣ | ណា | - | ស្ទឹងជីវ | ១៤ | [illegible] |
| ១០ | ទីម៉ រិត្នាវណ្ណ | | ១៧ | ព.ជ | ប្រុស | ១.២.៧៥ | ភឿន | ១១.៣.៧៧ | ស្ទឹងជីវ | ១៣ | |
| ១១ | ទីម៉ កូដារា | គុជ | ២០ | ព.ជ | ប្រុស | ៥.៧៤ | ម៉េង | - | រោងចក្រ | ១៣ | |
| ១២ | ម៉េង [illegible] | | ២៣ | ចាស់ | ស្រី | ៧៥ | | ៣០.៤.៧៧ | រដ្ឋករទឹក | ម.២ | រីយចាស់ |
| ១៣ | ហាយ សុខ | | ៧៦ | កម្មករចាស់ | ស្រី | ១៧.៤.៧៥ | អ.ក | ៥.៤.៧៧ | ដឹកជញ្ជូនជើងទឹក | ម.២ | - [illegible] |
| ១៤ | គ្រួយ ទាវ | | ៥០ | រីយចាស់ | ស្រី | | | ៥.៤.៧៧ | -៨- | ម.២ | រីយចាស់ [illegible] |
| ១៥ | ខៀវ ស៊ិន | ទឹម | ៣៧ | កម្មករ | ស្រី | ៥.២.៧០ | | ៥.៤.៧៧ | -៨- | ម.២ | [illegible] |
| ១៦ | ហាង ណាង | | ២៦ | ព.ជ | ប្រុស | ៨.៨.៧៣ | ញ៉ែម | ២.៧៦ | ៧០៣ | ១៣ | [illegible] |
| ១៧ | គឹម ហ៊ុច | ដឿន | ២៥ | អ.ត | ប្រុស | ៥.៩.៧០ | ផន | ២៦.២.៧៧ | ៣១០ | ១៣ | |
| ១៨ | អៀង ទេត | គុន ឥតឈ្មោះ | | ព.ជ | ប្រុស | ៩.១១.៧៣ | ផាន | ២៨.២.៧៧ | ៣១០ | ១៣ | |

ថ្ងៃទី ៧.៤.៧៧

00146611

D02358 TSL 5690 00007270

00146612

ការ/ហ·D19/VIII

បង យ៉ា

តាមការណែនាំរបស់បងឌុច ខ្ញុំសូមបងបញ្ជាក់ឲ្យច្បាស់ នឹងស្តុត អ៊ីវ៉ា សកម្មភាពក្បត់កន្លងមក តើបងសរសេរហើយឬ ! លើកម្លាំងដែលនៅប្រទេស ស៊ីអាងដូចម្តេច ! លើកម្លាំងដែលក្នុងប្រទេស ឲ្យនៅតែ ៥៤ តើបងសរសេរ កម្លាំង ដែលណាទៀត !

២៩. កញ្ញា. ៧៦

ឌុច

ខ្ញុំ ... [illegible]

~~[illegible]~~

~~[illegible]~~

~~[illegible]~~

~~[illegible]~~

ទី ... កញ្ញា ១៩៧៦ (...)

30.9.76

[signature]